**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចព្រមព្រៀង
# រវាង
# សណ្ឋាគារ សុខារ័ត្ន
# និង
# តំណាងកម្មករនិយោជិក
# ស្តីអំពីការព្យួរកិច្ចសន្យាការងារ

នៅថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០២០ វេលាម៉ោង ០៩ព្រឹក នៅក្នុងសណ្ឋាគារ **សុខារ័ត្ន** មានកិច្ចប្រជុំមួយរវាងតំណាងសណ្ឋាគារ និងតំណាងកម្មការនិយោជិក។

នៅក្នុងអង្គប្រជុំនេះ នាយកគ្រប់គ្រងទូទៅបានជូនដំណឹងដល់កម្មករនិយោជិកទាំងអស់អំពីស្ថានភាពបច្ចុប្បន្ននៅក្នុងសណ្ឋាគារថា ដោយសារសណ្ឋាគារគ្មានប្រាក់ចំណូល គឺមានតែចំណាយប្រចាំថ្ងៃ ដោយសារគ្មានភ្ញៀវទេសចរណ៍ណាមកស្នាក់នៅ ទាំងភ្ញៀវក្នុងស្រុក និងក្រៅប្រទេស ព្រោះតែវិបត្តិធ្ងន់ធ្ងរនៃជម្ងឺផ្លូវដង្ហើមវីរុសកូវីដ១៩ (COVID-19) មិនមានការធូរស្រាលនៅទូទាំងសកលលោក ហើយសណ្ឋាគារចង់រក្សាសុវត្ថិភាពជូនបុគ្គលិកនិយោជិកផងនោះ ក៏បានសម្រេចចិត្តធ្វើការព្យួរកិច្ចសន្យាការងាររបស់កម្មករនយោជិកទាំងអស់រយៈពេលចំនួន២ខែ ដោយគិតចាប់ពីថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០២០ រហូតដល់ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០២០។ នៅក្នុងអំឡុងពេលនៃការព្យួរការងារនេះ កម្មករនយោជិកទាំងអស់បានឯកភាពទទួលយកនូវការផ្តល់ជូនរបស់សណ្ឋាគារនូវប្រាក់ឈ្នួល ៥៥ដុល្លារអាមេរិកក្នុង១ខែ សម្រាប់កម្មករនយោជិកម្នាក់ៗ។

អង្គប្រជុំបានចប់វេលាម៉ោង ១០គត់ នាថ្ងៃខែឆ្នាំដដែល ដោយភាគីទាំងសងខាងមានភាពស្និតស្នាល និងការយោគយល់គ្នាក្រោមស្មារតីទទួលខុសត្រូវខ្ពស់ និងសហការគ្នាយ៉ាងរលូន។

សៀមរាប ថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ២០២០

**តំណាងកម្មករនយោជិក**

លោក ហោ គឿង

លោក កេង សុបិន

អ្នកនាង ម៉ា ចន្ថា

**នាយកក្រុមហ៊ុន**

**សុខ វីជា**